**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ: ៣០០៤ MIH / ២០១៧

រាជធានីភ្នំពេញ ថ្ងៃ០៩រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧

## ជម្រាបជូន
## លោកប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត

**កម្មវត្ថុ ៖** ករណីលុបបំបាត់សិប្បកម្មផលិតស្ករត្នោតក្លែងក្លាយ នៅតាមបណ្ដារាជធានី/ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប **លោកប្រធានមន្ទីរ** ជ្រាបថា ៖ កន្លងមកមានការផលិតស្ករត្នោតក្លែងក្លាយដែលបានផលិតចេញពីវត្ថុធាតុដើមស្ករស ឬស្ករផ្សេងទៀត ហើយបានកែច្នៃទៅជាផលិតផលស្ករដែលមានរសជាតិ ក្លិន ពណ៌ និងទ្រង់ទ្រាយដូចគ្នាទៅនឹងស្ករត្នោត និងបានយកទៅចរាចរលើទីផ្សារបន្លំធ្វើជាស្ករត្នោតខ្មែរ។ សកម្មភាពនេះ គឺជាវិច្ឆេទកម្មសេដ្ឋកិច្ចដើម្បីបំផ្លាញកិត្តិនាមស្ករត្នោតខ្មែរ ដែលជាអត្តសញ្ញាណផលិតផលជាតិកំពុងត្រូវបានទទួលស្គាល់ជាសាធារណៈទាំងក្នុង និងក្រៅប្រទេស។ ដូច្នេះ ក្រសួងសូមធ្វើការណែនាំដល់គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីខេត្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើការលុបបំបាត់រាល់សិប្បកម្មផលិតស្ករត្នោតក្លែងក្លាយ ចាប់ពីពេលនេះតទៅ។

អាស្រ័យហេតុនេះ សូម **លោកប្រធានមន្ទីរ** អនុវត្តតាមខ្លឹមសារការណែនាំខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម **លោកប្រធានមន្ទីរ** ទទួលនូវការរាប់អាន អំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន ៖</u>**
- គ្រប់សាលារាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ